## ខ្លឹមសាររដ្ឋធម្មនុញ្ញ និង សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

មុននឹងចាប់ផ្តើម គប្បីយើងចោទសួរខ្លួនយើងជាមុនថា អ្វីទៅដែលគេឱ្យឈ្មោះថា "រដ្ឋធម្មនុញ្ញ"នោះ? អ្វីទៅដែលមានសារៈសំខាន់ពិសេសទាល់តែមានការតម្រូវឱ្យបង្កើតស្ថាប័នកំពូលមួយឯករាជ្យសម្រាប់ការពារនោះ ?

គេបានចាត់ទុករដ្ឋធម្មនុញ្ញ ជាច្បាប់កំពូល ដែលរាល់ច្បាប់និងឯកសារគតិយុត្តទាំងឡាយនៅក្នុងប្រទេសនីមួយៗ ត្រូវអនុលោមទៅតាម បើពុំនោះសោតទេ ច្បាប់ និងឯកសារគតិយុត្តិទាំងនោះនឹងអធម្មនុញ្ញភាព។

ដូច្នេះតើនៅពេលណាទៅ គេត្រូវមានរដ្ឋធម្មនុញ្ញ ?

ចម្លើយថា គ្រប់សង្គមនយោបាយ ត្រូវមានអង្គនៃវិធានមួយចំនួនដែលគេបានចែង ឬ ក៏គេមិនបានចែងជាលាយលក្ខអក្សរ ដើម្បីកំណត់អំពីបែបបទនៃការបានទទួល និង ការបានក្តាប់អំណាចនយោបាយ ។

វិធានទាំងនេះ គឺជាមូលដ្ឋាននៃរដ្ឋធម្មនុញ្ញ ។

### I ~ អំពីសញ្ញាណនៃរដ្ឋធម្មនុញ្ញ

១ .ការព្រមទទួលយករដ្ឋធម្មនុញ្ញជាលាយលក្ខណ៍អក្សរ ជាបាតុភូតមួយថ្មី ដែលចាប់មាននៅពេលប្រទេសអាមេរិកបានទទួលឯករាជពីអាណានិគមក្នុងសតវត្សរ៍ទី១៨ ដោយបានបង្កើតចរន្តរដ្ឋធម្មនុញ្ញនិយមសម័យទំនើប ។ ប៉ុន្តែគំនិតអំពីសញ្ញាណនៃរដ្ឋធម្មនុញ្ញនោះ គេធ្លាប់មានតាំងពីអតីតកាលមករួចទៅហើយ។

នៅពេលដែលរដ្ឋមួយបានកើតហើយ គេមិនអាចគេចផុតបានទេពីបញ្ហាជាគ្រឹះនៃវិធានទាំងឡាយ ដែលយកចិត្តទុកដាក់នឹងអំណាចនយោ-បាយ ។

**បើតាមគំនិតនេះ អំណាចនយោបាយបណ្តាលមកពីកិច្ចសន្យាមួយ ។**

កិច្ចសន្យានេះ គឺជាកតិកាសញ្ញាមួយដែលចងភ្ជាប់ជាមួយគ្នា អ្នកដែលគ្រប់គ្រងគេ ( ឬអ្នកដឹកនាំ /អ្នកផ្តល់សេវា ) ជាមួយអ្នកដែលគេគ្រប់គ្រង (ឬប្រជារាស្ត្រ / អ្នកទទួលសេវា) ហើយដែលភាគីទាំងឡាយព្រមទទួលស្គាល់សិទ្ធិ និង កាតព្វកិច្ចទៅវិញទៅមក ។ កតិកាសញ្ញាដែលល្បីល្បាញជាងគេនោះ គឺ "កតិកាសញ្ញាធំ"(១) ឆ្នាំ១២១៥ មាន ៦០ មាត្រាដែលមហាក្សត្រអង់គ្លេសបានចុះកិច្ចសន្យាជាមួយ "អ្នកស្មើសក្តិគ្នា"(២) នៅក្នុងរាជាណាចក្រនោះ ។

**នេះគឺជាកិច្ចសន្យានៃការស្មោះត្រង់ ។**

ទ្រឹស្តីនៃកិច្ចសន្យានេះបានប្តូរន័យ នៅពេលដែលប្រជារាស្ត្រទាំងឡាយបានប្រែក្លាយទៅជាបុគ្គលស្វ័យត ដែលជាភាគីនៃកិច្ចសន្យា ។ ពួកគេមិនបានចុះកិច្ចព្រមព្រៀង ជាមួយអំណាចនៃរាជាធិបតេយ្យដែលមានពីមុននោះទេ ពួកគេបានចុះកិច្ចសន្យាតែជាមួយពួកគេ តែប៉ុណ្ណោះ ។កិច្ចព្រមព្រៀងនេះ បានបង្កើតអំណាចនយោបាយ ។នេះគឺជាទ្រឹស្តី "កិច្ចសន្យានៃសង្គម" ។

---

(១) la Grande Charte

(២)les pairs

## ២ . រដ្ឋធម្មនុញ្ញ គឺជាលក្ខន្តិកៈនៃអំណាច

រដ្ឋធម្មនុញ្ញជាប្រភពនៃភាពត្រូវច្បាប់ ។

គេមានសេចក្តីពន្យល់ផ្សេងៗគ្នា អំពីដើមកំណើតនៃអំណាច។ តាមផ្នែកគតិយុត្ត រដ្ឋធម្មនុញ្ញបានរៀបចំឱ្យមានសណ្តាប់ធ្នាប់ ក្នុងការពន្យល់នេះ។

•តាមពិត គ្រឹះអំណាចនៃអ្នកដែលគ្រប់គ្រងគេនោះ ស្ថិតនៅលើការចាត់តាំង ដែលអនុលោមតាមរដ្ឋធម្មនុញ្ញ ។ ការគោរពចំពោះកិច្ចការទាំងឡាយដែលគេបានធ្វើនោះ មិនមែនដោយសារបុគ្គលខ្លួនឯង ឬក៏ដោយសារប្រភពមួយមកពីក្រៅនោះទេ គឺដោយសារតែរដ្ឋធម្មនុញ្ញនោះឯង ។

•រាល់អំណាចទាំងឡាយដែលបានប្រគល់ឱ្យ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនោះ មានន័យថា ជាអំណាចពេញលក្ខណៈច្បាប់ទាំងអស់ដែលគេទុកជាត្រូវច្បាប់ ។ ការដែលប្រជារាស្ត្របានយល់ព្រមទទួលយករដ្ឋធម្មនុញ្ញនោះ បានធ្វើឱ្យគេយល់ថា ពួកគេព្រមទទួលយកអាជ្ញាធរមួយដែលកាន់កាប់អំណាច ដោយប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ។

•ពិតហើយ តម្លៃស្មើគ្នារវាងនីត្យានុកូលភាព[៣] ( លក្ខណៈដែលស្របច្បាប់ កំណត់ដោយច្បាប់) និង ធម្មានុរូបភាព[៤] (គុណភាពនៃអំណាចមួយដែលស្របទៅតាមបំណងប្រាថ្នារបស់ប្រជាជន ) នោះមិនមែនជាភាពមួយដែលដាច់ស្រឡះពីគ្នានោះទេ ។

---

(៣) légalité

(៤) légitimité

### ៣ . រដ្ឋធម្មនុញ្ញ គឺជាលក្ខណៈនៃទស្សនវិជ្ជានយោបាយ

រដ្ឋធម្មនុញ្ញមិនគ្រាន់តែជាកម្រងនៃនីតិវិធីប៉ុណ្ណោះទេ ពីព្រោះតាមការតាក់តែងនៃអត្ថបទ រដ្ឋធម្មនុញ្ញបានសំដែងពីចក្ខុវិស័យនៃសង្គម ដែលជាបំណងសម្រាប់នយោបាយមួយ ។

**ក-** គឺនៅក្នុងសេចក្តីប្រកាសអំពីសិទ្ធិទាំងឡាយនោះហើយ ដែលគេច្រើនសំដែងអំពីទស្សនវិជ្ជានៃរបបនយោបាយ ពីព្រោះនៅក្នុងសេចក្តីប្រកាសទាំងនោះ គេបានកំណត់ដោយច្បាស់ អំពីឋានៈនៃបុគ្គលនៅក្នុងសង្គមនយោបាយ ។

• ការទម្លាប់ដាក់សេចក្តីប្រកាសសិទ្ធិ ក្នុងចំណោមជើងពិស្តារនៃរដ្ឋ-ធម្មនុញ្ញនោះ គឺគេបានមកពីសហរដ្ឋអាមេរិក ។ នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៧៧៦ នៃរដ្ឋវៀរហ្ស៊ីនី (ស.រ.អ) មានចែងសេចក្តីប្រកាសអំពីសិទ្ធិដែលគេបានទុកធ្វើជាគំរូ នៅពេលក្រោយៗមក ។

• សេចក្តីប្រកាសពីសិទ្ធិមនុស្ស និង សិទ្ធិនៃពលរដ្ឋក្នុងឆ្នាំ១៧៨៩ នៃបដិវត្តន៍គហបតីបារាំង ដែលមាន ១៧ មាត្រា បានសំដែងអំពីទស្សនវិជ្ជាឯកត្តនិយម ក្នុងបំណងការពារបុគ្គល ពីអន្តរាគមន៍របស់រដ្ឋ ។

**ខ-** គេមិនបានដេញដោលអំពីសារៈសំខាន់គតិយុត្តិនៃបុព្វកថា និង នៃសេចក្តីប្រកាសនោះទេ ។ តើនេះជាវត្ថុធាតុមួយនៃទស្សនវិជ្ជា និង នៃរបៀបរៀបចំកម្មវិធី សម្រាប់ណែនាំអ្នកតែងច្បាប់នៅក្នុងពេលដែលពួកគេបំពេញកិច្ចការ ដោយមិនបានយកមកគិតអំពីសារៈសំខាន់នៃភាពបង្ខិតបង្ខំ ឬ ក៏ជាវិធានវិជ្ជមាន ដែលអំណាចសាធារណៈត្រូវតែគោរពនោះ ?

ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ដែលមាននៅក្នុងលទ្ធិប្រជាធិបតេយ្យសម័យទំនើបនេះ បានផ្តល់ចម្លើយមួយយ៉ាងច្បាស់ទៅនឹងសំណួរនេះ ។ វិធានទាំងឡាយដែលមាននៅក្នុងសេចក្តីប្រកាសអំពីសិទ្ធិបានបង្ខំអ្នកតាក់តែងច្បាប់ឱ្យទទួលវិធានទាំងនេះ ដោយមិនអាចបំពានបានពីព្រោះច្បាប់ដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ ត្រូវទទួលគ្រោះថ្នាក់នៃការប្រកាសអំពីអធម្មនុញ្ញភាព ។

៤ . រដ្ឋធម្មនុញ្ញ គឺជាលក្ខន្តិកៈសម្រាប់អ្នកដែលគ្រប់គ្រងគេ

នេះជាតំណែងដែលជាក់ស្តែងជាងគេរបស់រដ្ឋធម្មនុញ្ញ ព្រោះគេគ្រាន់តែមើលមួយត្រួសប៉ុណ្ណោះ គេក៏អាចនឹងយល់បានថាដូច្នេះមែន ។រដ្ឋធម្មនុញ្ញបានបង្កើតអំណាចសាធារណៈ កំណត់អំពីសមត្ថកិច្ច និង ចាត់ចែងការទាក់ទងរវាងអំណាចសាធារណៈទាំងនោះ ។ ដូច្នេះហើយបានជាតាមការប្រែប្រួលនៃវិធានទាំងនេះ គេអាចវាយតម្លៃបានអំពីនិត្យានុកូលភាពនៃកិច្ចការរបស់អំណាចសាធារណៈ ។

**II ~ តើមកដល់បច្ចុប្បន្ននេះ ប្រទេសកម្ពុជាយើងធ្លាប់មានរដ្ឋធម្មនុញ្ញប៉ុន្មានហើយ ? ហើយចាប់ពីពេលណាមក ?**

ប្រទេសកម្ពុជាយើង ចាប់មានរដ្ឋធម្មនុញ្ញ នៅពេលដែលព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ ព្រះចៅក្រុងកម្ពុជា ជារដ្ឋឯករាជ ជាភាគមួយក្នុងសហភាពបារាំងក្នុងឋានៈជាសមាគតរដ្ឋ ទ្រង់ប្រោសព្រះរាជទានដល់ប្រជារាស្ត្ររបស់ព្រះអង្គ ក្នុងក្របខ័ណ្ឌសីមា

នៃសន្ធិសញ្ញាទាំងឡាយ ដែលមានរវាងប្រទេសខ្មែរ និង ប្រទេសបារាំង នូវរដ្ឋធម្មនុញ្ញមួយ ដែលព្រះអង្គសព្វព្រះរាជហឫទ័យចុះព្រះហស្តលេខា នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ១៩៤៧ ។

## **២.១.រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា**( ឆ្នាំ១៩៤៧-១៩៥៣-១៩៧០)

ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ១៩៥៣ ប្រទេសកម្ពុជាបានទទួលឯករាជ្យមកវិញ ក្រោយពីពេលដែលខ្លួនបាត់បង់ឯករាជ្យនេះនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ១៨៦៣ ។ ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ១៩៥៣ កត់សម្គាល់ដំណើរការលូតលាស់មួយ ដែលធ្វើឱ្យប្រទេសឆ្លងកាត់ពីរដ្ឋក្នុងអាណាព្យាបាល មកជារដ្ឋអធិបតេយ្យ មួយជំហានម្តងៗ ដោយរក្សាក្របខ័ណ្ឌត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ។

ថ្ងៃទី ០៧ ខែ មករា ឆ្នាំ១៩៤៦ ព្រះអង្គម្ចាស់ **មុនីរ៉េត** ជាតំណាងព្រះមហាក្សត្រព្រះ **នរោត្តម សីហនុ** បានឡាយព្រះហស្តលេខាលើកិច្ចសន្យាបណ្តោះអាសន្ន[៥] ជាមួយរដ្ឋាភិបាលបារាំង ។ កិច្ចសន្យាបណ្តោះអាសន្ននេះបានបញ្ចប់ឧបការណ៍ដែលការកាន់កាប់របស់ជប៉ុន បានបើកផ្លូវតែមិនបាននាំ របៀបអាណាព្យាបាលបារាំងមកវិញទេ ។ កិច្ចសន្យាបណ្តោះអាសន្ន បានបើកផ្លូវឱ្យមានស្វយ័តភាពផ្ទៃក្នុង ដែលតម្រូវឱ្យមានការធានាដោយរដ្ឋធម្មនុញ្ញមួយ ។

---

(៥) modus vivendi

គណៈកម្មការបារាំង-ខ្មែរមួយ បានតាក់តែងសេចក្តីព្រាងរដ្ឋធម្មនុញ្ញមួយជាលើកដំបូង ហើយបានដាក់ថ្វាយព្រះមហាក្សត្រ ។ ព្រះអង្គបានផ្តល់ការកែប្រែពីរ យ៉ាងសំខាន់ គឺចំពោះលក្ខណៈជ្រើសតាំងនៃរាជាធិបតេយ្យ និងការបោះឆ្នោតរដ្ឋសភាជាសាកល ។ ក្រោយការបោះឆ្នោតថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ១៩៤៦ ដែលជាការបោះឆ្នោតនៃលទ្ធិប្រជាធិបតេយ្យមែនទែន មិនធ្លាប់បានរៀបចំនៅក្នុងប្រទេសនោះ រដ្ឋសភាបានរៀបចំអត្ថបទរដ្ឋធម្មនុញ្ញមួយរបស់ខ្លួនផ្ទាល់ ដែលបន្ទាប់មក បានយកទៅចរចាជាមួយព្រះមហាក្សត្រ ។

រដ្ឋធម្មនុញ្ញមួយ ដែលមានអត្ថបទខុសគ្នាបន្តិចបន្តួចជាមួយសេចក្តីព្រាងរបស់រដ្ឋសភា បើសិនគេគិតអំពីអត្ថរសនោះ ត្រូវបានព្រះមហាក្សត្រប្រោសប្រទានដល់ប្រជារាស្ត្ររបស់ព្រះអង្គ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ១៩៤៧ ។

ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ១៩៤៩ បារាំងបានទទួលស្គាល់តាមផ្លូវច្បាប់នូវឯករាជ្យនៃរាជាណាចក្រកម្ពុជា ។ ប៉ុន្តែអធិបតេយ្យនេះ ត្រូវបានរិតត្បិតដោយលក្ខន្តិកៈជា "រដ្ឋសមាជិកសមាគមក្នុងក្របខ័ណ្ឌនៃសហភាពបារាំង"[៦] ។

ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ១៩៥៣ ព្រះមហាក្សត្រចាប់ផ្តើមធ្វើអ្វីដែលព្រះអង្គបានដាក់ឈ្មោះថា "ព្រះរាជបូជនិយកិច្ចដើម្បីកម្ពុជាឯករាជ្យ" ។ ព្រះអង្គបានយាងចេញពីរាជធានីភ្នំពេញ ទៅគង់នៅតំបន់ស្វយ័តដែលមាននៅខេត្តកំពង់ធំ ខេត្តសៀមរាប និង ខេត្តបាត់ដំបង ក្រោយបានទទួល

(៦) Etat associé dans le cadre de l’Union Française

ស្វយ័ភាពយោធាពីបារាំង ។

នៅខែកក្កដាឆ្នាំដដែល រដ្ឋាភិបាលខ្មែរនិងបារាំងបានប្តូរសារគ្នាទៅវិញទៅមក ដើម្បីផ្តល់អធិបតេយ្យដល់ប្រទេសខ្មែរ ចំពោះកិច្ចការបរទេស ។ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំដដែល បារាំងបានផ្ទេរអំណាចតុលាការ និងអំណាចនគរបាលជូនខ្មែរវិញ ហើយនៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំដដែល មានចុះហត្ថលេខាឱទ្ទេសអធិបតេយ្យយោធារបស់ប្រជាពលរដ្ឋខ្មែរ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជារបស់ខ្លួន ។ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំដដែល ព្រះមហាក្សត្រយាងត្រឡប់មកកាន់រាជធានីភ្នំពេញវិញ ហើយមួយថ្ងៃបន្ទាប់មក ពិធីបុណ្យឯករាជ្យត្រូវបានប្រារព្ធឡើង ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ នៅជាធរមានដដែល ។

ច្បាប់កំពូលនេះ ត្រូវបានកែប្រែជាបន្តបន្ទាប់ ដើម្បីសម្របជាមួយការវិវត្ត និង ដំណើរការប្រែប្រួលនៃនយោបាយ ។ ព្រះមហាក្សត្របានដាក់រាជ្យសម្បត្តិ ដើម្បីថ្វាយទៅព្រះវររាជបិតានៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ១៩៥៥ ។ របបសង្គមរាស្ត្រនិយមក៏ត្រូវបានបង្កើតឡើង ក្រោយពីចលនាសង្គមរាស្ត្រនិយមបានទទួលជោគជ័យទាំងស្រុង ក្នុងការបោះឆ្នោតសាកលពីថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ១៩៥៥ ។

រដ្ឋធម្មនុញ្ញទី១នេះ (គិតមកដល់រដ្ឋប្រហារថ្ងៃទី ១៨ ខែ មីនា ឆ្នាំ១៩៧០) ត្រូវបានធ្វើការសើរើ និង ធ្វើវិសោធនកម្មចំនួន ១២ លើក និង ចែកចេញ ជា ១២ ជំពូក និង មាន ១២២ មាត្រា ។

## ២.២. រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ( ឆ្នាំ១៩៧០ - ១៩៧៥ )

ក្រោយរដ្ឋប្រហារថ្ងៃទី ១៨ ខែ មីនា ឆ្នាំ១៩៧០ ប្រទេសកម្ពុជាបានប្តូររបបរាជានិយម ទៅជារបបសាធារណរដ្ឋខ្មែរ ។ ការគ្រប់គ្រងប្រទេសត្រូវបានផ្លាស់ប្តូរទាំងស្រុង ទោះបីពុំទាន់មានរដ្ឋធម្មនុញ្ញថ្មីមកជំនួសក៏ដោយ ។ តាមរបបយោធា ច្បាប់ទាំងឡាយត្រូវបានរក្សាទុកជាធរមាន វៀរលែងតែបទបញ្ញត្តិណាដែលផ្ទុយនឹងរបបសាធារណរដ្ឋ ។

រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរត្រូវបានគណៈកម្មការមួយតាក់តែងចប់សព្វគ្រប់ នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ១៩៧២ ហើយត្រូវបានទទួលការយល់ព្រមពីប្រជាមតិ នៅថ្ងៃទី ៣០ ខែ ឆ្នាំដដែល ដោយនៅពេលនោះគេមានអ្នកបោះឆ្នោតចំនួន ១.៥៦ លាននាក់ បើគិតជាភាគរយ គឺ ៩៧,៥% យល់ព្រមទទួលយកសេចក្តីព្រាងនេះ ( នៅក្នុងចំណោមមនុស្សប្រហែល ៧ លាននាក់ ដែលជិតពាក់កណ្តាលជាមនុស្សគ្រប់អាយុបោះ-ឆ្នោត ។ រដ្ឋាភិបាលសាធារណរដ្ឋខ្មែរត្រួតត្រាពាក់កណ្តាលដែនដី និង ៣/៤ នៃប្រជាជនទាំងមូល ) ។

រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរត្រូវបានប្រកាសឱ្យប្រើ តាមបញ្ញត្តិរបស់ប្រធានាធិបតី លេខ ១៩/៧២-បសខ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ១៩៧២ ។

រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ប្រកាន់យករបបប្រធានាធិបតីនិយមតាមបែបសហរដ្ឋអាមេរិក ។ ប្រធានាធិបតីជាប្រមុខរដ្ឋផង និង ជានាយករដ្ឋមន្ត្រីផង ។

រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរនេះចែកចេញជា ១១ ជំពូក និង មាន ១២១ មាត្រា ហើយក៏មានមាត្រាអវសានមួយផងដែរ ។

## ២.៣.រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ( ឆ្នាំ១៩៧៥-១៩៧៩ )

នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ពួកខ្មែរក្រហមបានចូលទីក្រុងភ្នំពេញ ហើយបានតាំងរបបមួយដែលមានឈ្មោះជា " កម្ពុជាប្រជាធិបតេយ្យ " ។

សម័យប្រជុំមួយរបស់ពួកកម្មាភិបាល នាទីក្រុងភ្នំពេញពីថ្ងៃទី ២៥ ដល់ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ១៩៧៥ បានសម្រេចលើអត្ថបទមួយនៃរដ្ឋធម្មនុញ្ញ ហើយក្រោយមកមហាសន្និបាតជាតិលើកទី៣ បានអនុម័តយល់ព្រមលើរដ្ឋធម្មនុញ្ញនេះ នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ១៩៧៥ ។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ១៩៧៦ ។

រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យចែកចេញជា ១៦ ជំពូក និងមាន ២១ មាត្រា ។

## ២.៤.រដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា

( ឆ្នាំ១៩៧៩ - ១៩៨៩ )

ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ១៩៧៨ នៅក្នុងតំបន់ចន្លោះស្រុកស្នួលនិងព្រំដែនវៀតណាម ដែលជាតំបន់ស្ថិតនៅក្រៅតំបន់គ្រប់គ្រងរបស់អាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ មានកម្មាភិបាលតំបន់បូពា ប្រហែលជា ២០០នាក់

បានរួមប្រជុំជាមួយយោធាច្រើនរយនាក់ ( អ្នកទាំងអស់នេះ បានភៀសខ្លួនទៅប្រទេសវៀតណាម តាំងតែពី ខែមិថុនា ឆ្នាំ១៩៧៧ ) បង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និង បានចាប់ផ្តើមធ្វើការប្រយុទ្ធនឹងរបប ប៉ុល ពត ។ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ហើយដែលតាមការអំពាវនាវរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា មានការសហការអំពីកងទ័ពស្ម័គ្រចិត្តវៀតណាមផងនោះ បានវាយផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ( ខ្មែរក្រហម) ។ ភ្នំពេញត្រូវបានរំដោះនៅថ្ងៃទី ០៧ ខែ មករា ឆ្នាំ១៩៧៩ ។

ថ្ងៃបន្ទាប់មក ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជាត្រូវបានបង្កើតឡើង ហើយនៅថ្ងៃទី ១២ ខែ មករា ឆ្នាំ១៩៧៩ បានប្រកាសប្រទេសកម្ពុជាជា " សាធារណរដ្ឋប្រជាមានិតកម្ពុជា " ។ ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា បានបន្តគ្រប់គ្រងប្រទេសរហូតដល់ខែ កក្កដា ឆ្នាំ១៩៨១ រួចមកត្រូវបានជំនួស ដោយក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបង្កើតនោះ ។

នៅថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ១៩៨១ មានការបោះឆ្នោតជាសាកលមួយ ដើម្បីជ្រើសរើសសមាជិករដ្ឋសភា ចំនួន ១១៧ រូប ក្នុងចំណោមបេក្ខជនដែលមានឈ្មោះក្នុងបញ្ជីតែមួយ ។ ភារកិច្ចដំបូងរបស់រដ្ឋសភានេះ មានការពិនិត្យ និង អនុម័តសេចក្តីព្រាងរដ្ឋធម្មនុញ្ញ ដែលក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជាបានធ្វើមក ។ សេចក្តីព្រាងរដ្ឋធម្មនុញ្ញត្រូវបានរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជាអនុម័តជាឯកច្ឆ័ន្ទ នៅ

ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ១៩៨១ នាសម័យប្រជុំលើកទី១ នីតិកាលទី១ ហើយត្រូវបានក្រុមប្រឹក្សារដ្ឋប្រកាសឱ្យប្រើ តាមក្រឹត្យលេខ ០១ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ១៩៨១ និង ត្រូវចូលជាធរមាន នៅថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ១៩៨១ ។ រដ្ឋធម្មនុញ្ញនេះចែកចេញជា ១០ ជំពូក និង មាន ៩៣ មាត្រា ។

## ២.៥-រដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា ( ឆ្នាំ១៩៨៩ - ១៩៩៣ )

រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាមូលដ្ឋានច្បាប់ជាសារវ័ន្ត ដែលទ្រទ្រង់នីត្យានុកូលភាពរបស់រដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា អស់រយៈពេលជាង១០ឆ្នាំទៅហើយនោះ ត្រូវបានកែសម្រួលមាត្រាខ្លះ អស់ចំនួន ០៤ លើករួចមកហើយ ។ ការកែប្រែទាំងនោះ បានផ្ដើមចេញពីការវិវត្ត និង ការរីកចម្រើនរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ជាបំណងប្រាថ្នានិងសេចក្ដីត្រូវការក្នុង ជីវភាពនយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ចរបស់ប្រជាជន ។

នៅក្នុងរយៈពេល១០ឆ្នាំ សាធារណរដ្ឋប្រជាមានិតកម្ពុជាបាននាំមកនូវសមិទ្ធផលសង្គមលើគ្រប់វិស័យ ធ្វើឱ្យមាតុភូមិប្រែប្រួលមុខមាត់ថ្មី ជីវ-ភាពខាងស្មារតី និង សម្ភាររបស់សង្គម ជាជំហាន១កាន់តែកើនឡើង។ ការវិវត្តនិងការរីកចម្រើននេះ បាននាំមកនូវតម្រូវការថ្មីៗមួយចំនួន ដែលចាំបាច់ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា យកចិត្តទុកដាក់កែសម្រួលគោលនយោបាយមួយចំនួនជាបន្តបន្ទាប់ ជាពិសេស គោលនយោបាយ

សំខាន់ៗទាំង ៥ ដែលបានដាក់នៅមហាសន្និបាតកម្មាភិបាលទូទាំងប្រទេស លើកទី២ ពិនិត្យ និង អនុម័ត ។ ទន្ទឹមនឹងនេះក្នុងសម័យប្រជុំរដ្ឋសភា លើកទី១៦ នីតិកាលទី១ រដ្ឋសភាបានផ្តួចផ្តើមគំនិតចាំបាច់ នៃការកែទម្រង់ខាងនយោបាយ ដើម្បីជម្រុញ និងសន្ទុះរីកចម្រើន ថែមទៀត ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា មានបំណងបញ្ចេញឆន្ទៈបើកចំហ ដែលបានចារក្នុងបរិការណ៍ថ្មីមួយ កើតមកពីការអំពាវនាវបង្រួបបង្រួមជាតិ របស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានដំណើរការនៅខែ សីហា ឆ្នាំ១៩៨៧ ក្រោយពេលជំនួបកាលពីខែ ធ្នូ ឆ្នាំ១៩៨៧ និង ខែ មេសា ឆ្នាំ១៩៨៨ រវាងសម្តេចព្រះ**នរោត្តម សីហនុ** និងឯកឧត្តម **ហ៊ុន សែន** និង ដោយជំនួបក្រៅផ្លូវការនៅទីក្រុង ស្សារការតា ហ្ស៊ីម១ ( **JIM I**)[៧] និង ហ្ស៊ីម២ (**JIM II**)[៨] ដែលប្រមូលភាគីប្រយុទ្ធទាំងអស់ នៅរដ្ឋធានីឥណ្ឌូនេស៊ី ក្នុងខែ កក្កដា ឆ្នាំ១៩៨៨ និងខែ កុម្ភៈ ឆ្នាំ១៩៨៩ ។

ផ្តើមចេញពីទស្សនេះ នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ១៩៨៩ ក្រុមប្រឹក្សារដ្ឋ បានសម្រេចចាត់តាំងគណៈកម្មការកែសម្រួលរដ្ឋធម្មនុញ្ញ ដែលមានសមាសភាព ២៤ រូប បែងចែកជា ០៣ អនុគណៈកម្មការ ។

សេចក្តីព្រាងកែសម្រួលរដ្ឋធម្មនុញ្ញ ជាលទ្ធផលនៃការខិតខំប្រឹងប្រែង របស់គណៈកម្មការ ដែលមានសមាសភាពមកពីស្ថាប័នបក្ស រដ្ឋសភា រណសិរ្ស អង្គការមហាជន រួមទាំងអតីតឥស្សរជនខ្មែរ នៅប្រទេសបារាំង

(៧) Jakarta Informal Meeting I

(៨) Jakarta Informal Meeting II

និងសហរដ្ឋអាមេរិក មានជាអាទិ៍ លោក **អ៊ិន តាំ** លោកនិងលោកស្រី **ពុង ប៉េងចេង** និង លោក **ថៅ ប៉េងលាត** ដែលនៅពេលនោះមាន ឯកឧត្តម **ហ៊ុន សែន** ជាអ្នកដឹកនាំ ។ សេចក្តីព្រាងកែសម្រួលរដ្ឋធម្មនុញ្ញនេះ ត្រូវបានដាក់ជូនសម័យប្រជុំវិសាមញ្ញមួយ របស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅថ្ងៃទី ២៩ និង ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៨៩ ហើយដែលរដ្ឋសភានេះបានអនុម័ត និង ក្រុមប្រឹក្សារដ្ឋបានប្រកាសឱ្យប្រើ ដោយក្រឹត្យលេខ ២៩ ក្រ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៨៩ ។ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជានេះ ចែកចេញជា ១០ ជំពូក និង ៩៣ មាត្រា ។

## ២.៦-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ១៩៩១ អត្ថបទទាំងបួនដែលជា " កិច្ចព្រមព្រៀង ដើម្បីដោះស្រាយទំនាស់ទាំងអស់នៅកម្ពុជា " ត្រូវបានចុះហត្ថលេខានៅទីក្រុងប៉ារិស ។ ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ គេត្រូវវាយនៅទូទាំងកម្ពុជានូវកងទ័ពអង្គការសហប្រជាជាតិ ដែលមានឈ្មោះថា " អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា" (៩) ។ អាជ្ញាធរនេះមានភារកិច្ចជាអាទិ៍ រៀបចំការបោះឆ្នោត " សេរី និង ត្រឹមត្រូវ " ជ្រើសតាំងសភាធម្មនុញ្ញ ដើម្បីរៀបចំ "ធម្មនុញ្ញ" មួយជាគោលដែលគោរពគោលការណ៍ ដូចបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀង ។

---

(៩) **APRONUC**

ការបោះឆ្នោតត្រូវបានប្រព្រឹត្តទៅ ពីថ្ងៃទី ២៣ ដល់ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ១៩៩៣ ហើយសភាធម្មនុញ្ញ ត្រូវបានដំណើរការនៅ ថ្ងៃទី ១៤ ខែ មិថុនា ។

នៅថ្ងៃទី ២១ ខែ កញ្ញា ដោយ ១១៣ សម្លេងស្រប ០៥សម្លេងប្រឆាំង និង ០២ សម្លេង អនុបវាទ សភាធម្មនុញ្ញបានអនុម័តរដ្ឋធម្មនុញ្ញជាគោលមួយ ។ រដ្ឋធម្មនុញ្ញជាគោលថ្មីនេះ ត្រូវបាន សម្តេច **នរោត្តម សីហនុ** ព្រះប្រមុខរដ្ឋ ប្រកាសឱ្យប្រើនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ១៩៩៣។ នៅក្នុងថ្ងៃដដែល បន្ទាប់ពីបានទទួលការទូលស្នើពីក្រុមប្រឹក្សារាជបល្ល័ង្ក សម្តេច **នរោត្តម សីហនុ** បានសច្ចាប្រណិធាន ដែលធ្វើឱ្យព្រះអង្គក្លាយទៅជាព្រះមហាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញ ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មកដល់ខែមីនា ឆ្នាំ២០០៨ បានធ្វើវិសោធនកម្ម ចំនួន ០៦ លើក គឺក្នុងខែ÷

- កក្កដា ឆ្នាំ ១៩៩៤
- មីនា ឆ្នាំ ១៩៩៩
- កក្កដា ឆ្នាំ ២០០១
- មិថុនា ឆ្នាំ ២០០៥
- មីនា ឆ្នាំ ២០០៦ និង
- កុម្ភៈ ឆ្នាំ ២០០៨ ។

ដោយឡែក ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី

នៃស្ថាប័នជាតិ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ និង បានធ្វើវិសោធនកម្មមួយមាត្រា គឺមាត្រា ០៦ ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានបុព្វកថាមួយ ដែលផ្អែកលើប្រពន្ធ័ប្រជាធិបតេយ្យសេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើង រីកចំរើន លូតលាស់ សម្បូររុងរឿងជានិច្ចនិរន្តរ៍ ។ រដ្ឋធម្មនុញ្ញនេះ ចែកជា ១៦ ជំពូក ដែលមានសរុបទាំងអស់ ១៥៨ មាត្រា :

ជំពូកទី១ អំពីអធិបតេយ្យ មាន ៦មាត្រា គឺពីមាត្រា ០១ ដល់មាត្រា ០៦ ដែលមានចែងជាអាទិ៍ថា ព្រះមហាក្សត្រ ទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និង តាមលទ្ធិប្រជាធិតេយ្យសេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ មិនអាចបំបែកបាន។

ភាសា និង អក្សរ ដែលប្រើជាផ្លូវការ គឺភាសា និង អក្សរខ្មែរ ។

ជំពូកទី២ អំពីព្រះមហាក្សត្រ មាន ២៤មាត្រា គឺពីមាត្រា ០៧ ដល់មាត្រា ៣០ ថ្មី ដែលមានចែងជាអាទិ៍ថា : ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។ ព្រះអង្គគង់ជាប្រមុខរដ្ឋមួយជីវិត ហើយក៏មិនអាចមាននរណារំលោភបំពានបានឡើយ ។

របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង ។ ព្រះមហាក្សត្រ ទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទ សម្រាប់គ្រងរាជសម្បត្តិឡើយ ។

ប្រការដែលមានចែងថា" ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ..." មិនអាចសុំកែប្រែបានជាដាច់ខាត ។

ព្រះមហាក្សត្រ ព្រះអង្គទាក់ទងជាមួយព្រឹទ្ធសភា និង រដ្ឋសភា ដោយព្រះរាជសារ តែព្រះរាជសារនេះ ព្រឹទ្ធសភា និង រដ្ឋសភា មិនអាចយកទៅជជែកពិភាក្សាឡើយ ។

ព្រះអង្គទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និង តែងតាំងគណៈរដ្ឋមន្ត្រី ។

ព្រះអង្គទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ និង ទ្រង់គង់ជាអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ទ្រង់ប្រកាសសង្គ្រាមក្រោយការអនុមត័របស់រដ្ឋសភា និង ព្រឹទ្ធសភា ។

ព្រះអង្គទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និង លើកលែងទោស ។

ជំពូកទី៣ អំពីសិទ្ធិ និង ករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ មាន ២០មាត្រា គឺពីមាត្រា ៣១ ដល់មាត្រា ៥០ ។

ជំពូកនេះមានចែងជាអាទិ៍ថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំង អនុសញ្ញាទាំងឡាយទាក់ទងនិងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ ។

ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និង សន្តិសុខផ្ទាល់ខ្លួន ។ ទោសប្រហារជីវិតមិនត្រូវមានឡើយ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និង អាចឈរឈ្មោះឱ្យគេបោះឆ្នោត មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពតិមាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និង ដល់សន្តិសុខជាតិ បានឡើយ។

ច្បាប់ការពារមិនឱ្យមានការរំលោភបំពាន លើរូបរាងកាយបុគ្គលណាមួយឡើយ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។

វិមតិសង្ស័យ ត្រូវជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ ។ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។

បុរស និង ស្រ្តី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និង គ្រួសារ ។

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និង អំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និង គោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និង កម្មសិទ្ធិស្របច្បាប់របស់ឯកជន។

ជំពូកទី៤ អំពីរបបនយោបាយ មាន ៥ មាត្រា គឺពីមាត្រា ៥១ ថ្វី ដល់មាត្រា ៥៥ ។ ជំពូក នេះមានចែងជាអាទិ៍ថា ៖ ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ហើយប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និង សាលាជម្រះក្តី ។

អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ ។

រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញារក្សា ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សាការពារទំនៀមទម្លាប់ និង ប្រពៃណីល្អរបស់ជាតិ។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ ។

ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ច នូវនយោបាយអព្យាក្រឹត អចិន្ត្រៃយ៍ និង មិនចូលបក្សសម្ព័ន្ធ។

ការផលិត ការប្រើប្រាស់ ការរក្សាទុកអាវុធបរមាណូ អាវុធគីមី ឬ អាវុធវេត្រាណូ ត្រូវហាមឃាត់ដាច់ខាត ។ សន្ធិសញ្ញា និង កិច្ចព្រមព្រៀងទាំងឡាយណាដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹតភាព និង ឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល ។

ជំពូកទី៥ អំពីសេដ្ឋកិច្ច មាន ៩ មាត្រា គឺពីមាត្រា ៥៦ ដល់មាត្រា ៦៤ ។ នៅក្នុងជំពូកនេះ មានចែងជាអាទិ៍ថា " ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ " ។

ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថាជារបស់រដ្ឋ ។

រដ្ឋហាមឃាត់និងផ្តន្ទាទោសជាទម្ងន់ដល់ជនណា ដែលនាំចូល ផលិត លក់ដូរគ្រឿងញៀន ទំនិញក្លែងក្លាយ ហួសរយៈពេលប្រើ ដែលប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើ ។

ជំពូកទី៦ អំពីអប់រំ វប្បធម៌ និង សង្គមកិច្ច មាន ១១ មាត្រា គឺពីមាត្រា ៦៥ ដល់មាត្រា ៧៥ ។

នៅជំពូកនេះមានចែងជាអាទិ៍ថា រដ្ឋត្រូវការពារ និង លើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កម្រិត និង ត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំ

នេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។ រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និង មធ្យមសិក្សានៅសាលារៀនសាធារណៈ សម្រាប់ប្រជាពលរដ្ឋគ្រប់រូប ដោយឥតបង់ថ្លៃ ហើយប្រជាពលរដ្ឋត្រូវបានទទួលការអប់រំ យ៉ាងតិច ប្រាំបួនឆ្នាំ ។

បរិវេណបេតិកភ័ណ្ឌជាតិ ក៏ដូចជាបេតិកភ័ណ្ឌដែលបានបញ្ចូលជា បេតិកភ័ណ្ឌពិភពលោក ត្រូវទុកជាតំបន់អព្យាក្រឹត ដែលមិនឱ្យមាន សកម្មភាពយោធា ( មាត្រា ៧១ )

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ហើយត្រូវឧបត្ថម្ភជនពិការ និងគ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ក៏ដូចជាចាត់ចែង ឱ្យមានរបបសន្តិសុខសង្គម ដល់កម្មករ និង និយោជិត ។

ជំពូកទី៧ អំពីរដ្ឋសភា ដែលមាន ២៣ មាត្រា គឺពីមាត្រា ៧៦ ដល់ មាត្រា ៩៨ ថ្មី ។

រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០រូប តាមការ ជ្រើសតាំងដោយការបោះឆ្នោត ជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និង តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។ អ្នកដែលមាន សិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិជាខ្មែរ តាំងពីកំណើត ។

តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ។ អាណត្តិអាជ្ញាបញ្ជាទាំងឡាយ ត្រូវទុកជាមោឃៈ ។

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬ ពី គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។

ក្នុងកាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ហើយនៅពេលដែលប្រទេសជាតិឋិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ ។

ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬ ការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអាសាសូន្យ ។ ក្រុមប្រឹក្សាធម្មនុញ្ញគឺជាអង្គការ តែមួយគត់ ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ ។

តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ។ រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ សម្រាប់ការឆ្លើយសំណួរ ។

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។

ជំពូកទី៨ ថ្មី អំពីព្រឹទ្ធសភា មាន ១៧ មាត្រា គឺពីមាត្រា ៩៩ ថ្មី ដល់មាត្រា ១១៥ ថ្មី ។

ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ដែលបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន ។

សមាជិកព្រឹទ្ធសភា មានយ៉ាងច្រើនស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាចំនួនពីររូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងពីររូបទៀត ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប។

រីឯសមាជិកព្រឹទ្ធសភាឯទៀត ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកល ។ នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ០៦ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

ក្នុងពេលមានសង្គ្រាម ឬ ក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា ។ ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ។ ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និង រដ្ឋាភិបាល ។

ជំពូកទី៩ ថ្មី អំពីសមាជរដ្ឋសភា និង ព្រឹទ្ធសភា មាន ០២ មាត្រា គឺមាត្រា១១៦ ថ្មី និង មាត្រា ១១៧ ថ្មី ដែលបញ្ជាក់ថា " ក្នុងករណីចាំបាច់ រដ្ឋសភា និង ព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ " ។

ជំពូកទី ១០ ថ្មី អំពីរាជរដ្ឋាភិបាល មាន ១០ មាត្រា គឺពីមាត្រា ១១៨ ថ្មី ( ៩៩ ចាស់ ) ដល់ មាត្រា ១២៧ ថ្មី ( មាត្រា ១០៨ ចាស់ ) ។

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ ជាសមាជិក ។

តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រ ទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោតឱ្យបង្កើតរាជរដ្ឋាភិបាល ។

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅ របស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរៀងៗខ្លួន ចំពោះនាយករដ្ឋមន្ត្រី និង ចំពោះរដ្ឋសភា អំពីការដែលខ្លួនបានប្រព្រឹត្ត ។

ជំពូកទី ១១ ថ្មី អំពីអំណាចតុលាការ មាន ០៨ មាត្រា គឺពីមាត្រា១២៨ ថ្មី ( មាត្រា១០៩ ចាស់ ) ដល់មាត្រា ១៣៥ ថ្មី ( មាត្រា ១១៦ ចាស់ ) ។

អំណាចតុលាការជាអំណាចឯករាជ្យ គ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និង សាលាជម្រះក្តីគ្រប់ផ្នែក និង គ្រប់ជាន់ថ្នាក់ ។

ការជម្រះក្តីផ្តល់យុត្តិធមិ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន។ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និង ឱ្យអស់ពីដួងចិត្ត និង សម្បជញ្ញៈរបស់ខ្លួន ។

គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬ នីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេច ដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។

ជំពូកទី ១២ ថ្មី អំពីក្រុមប្រឹក្សាធម្មនុញ្ញ មាន ០៩ មាត្រា គឺពីមាត្រា ១៣៦ ថ្មី ដល់មាត្រា ១៤៤ ថ្មី ។

ចំពោះជំពូកនេះ អនុញ្ញាតឱ្យខ្ញុំបើកវង់ក្រចក ដើម្បីបកស្រាយឱ្យបានល្អិតបន្តិច ចំពោះសមត្ថកិច្ចនៃក្រុមប្រឹក្សាធម្មនុញ្ញ។

នៅខាងដើមនៃបទឧទ្ទេសនាម ខ្ញុំបានចោទសួរថា អ្វីទៅដែលគេឱ្យឈ្មោះថា " រដ្ឋធម្មនុញ្ញ " និង អ្វីទៅដែលមានសារៈសំខាន់ពិសេស ទាល់តែមានការតម្រូវឱ្យបង្កើតស្ថាប័នកំពូលមួយឯករាជ្យ សម្រាប់ការពារនោះ? ខ្ញុំក៏បានអត្ថាធិប្បាយជូនរួចហើយដែរដូចខាងដើម។ តែនៅខណៈនេះ ខ្ញុំសូមបញ្ជាក់អំពីស្ថាប័នកំពូលនេះ ដែលមានសមត្ថកិច្ចការពាររដ្ឋធម្មនុញ្ញ។

មាត្រា ១៣៦ ថ្មី ចែងថា "ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភា បានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និង សម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា " ។

ម៉្យាងទៀត សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញក៏ត្រូវបានបញ្ជាក់ក្នុងបទប្បញ្ញត្តិនៃមាត្រា៩២ ដូចបានរៀបរាប់ក្នុងជំពូកអំពីរដ្ឋសភារួចហើយ។

តើក្រុមប្រឹក្សាធម្មនុញ្ញ ធានាការពារការគោរពរដ្ឋធម្មនុញ្ញនោះ តាមបែបណា?

ចម្លើយថា បទប្បញ្ញត្តិនៃមាត្រា ១៥០ ថ្មី នៃរដ្ឋធម្មនុញ្ញ បានចែងថា "រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់ និង សេចក្តី

សម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត " ។

**ក~** ដូច្នេះ ការធានា ការពារការគោរពនេះ គឺការពារកុំឱ្យច្បាប់និងសេចក្ដីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ មានលក្ខណៈផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញ ។

ពិតហើយ ការផ្ដើមគំនិតសេរី ឬការផ្ដើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្ដីស្នើរបស់តំណាងរាស្ត្រមួយភាគបួន (១/៤) នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។ ដោយឡែកមាត្រា ១៤៣ ថ្មីនៃរដ្ឋធម្មនុញ្ញ បានចែងថា ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សា-ធម្មនុញ្ញ ចំពោះសេចក្ដីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ។

**ខ~**ក្រុមប្រឹក្សាធម្មនុញ្ញធានា ការពារការគោរពរដ្ឋធម្មនុញ្ញ ដោយពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ។ មាត្រា ១៤០ ថ្មី ចែងថា "ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួន មួយភាគដប់ (១/១០) ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភា ចំនួនមួយភាគបួន (១/៤) អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័ត ទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងច្បាប់នោះត្រូវប្រកាសឱ្យប្រើ " ។

"បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឱ្យប្រើ ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចក្នុងរយៈពេលសាមសិម

(៣០) ថ្ងៃយ៉ាងយូរ ថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើ ស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ "។

មាត្រា ១៤១ ថ្មី ចែងថា " ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន(១/៤) តំណាងរាស្ត្រចំនួនមួយភាគដប់(១/១០) ឬ តុលាការ អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ "។

រីឯមាត្រា ១៥ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏បានបញ្ជាក់ផងដែរថា ក្រុម-ប្រឹក្សាធម្មនុញ្ញបកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់។

គេអាចមានសំណួរថា តើប្រជារាស្ត្រ អាចស្នើក្រុមប្រឹក្សាធម្មនុញ្ញឱ្យបកស្រាយរដ្ឋធម្មនុញ្ញបានដែរឬទេ?

**ចម្លើយ**

**ក**~ប្រជារាស្ត្រ ធ្វើសំណើឆ្លងតាមរយៈប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន(១/៤) ឬតំណាងរាស្ត្រចំនួនមួយភាគដប់(១/១០) សុំក្រុមប្រឹក្សាធម្មនុញ្ញឱ្យបកស្រាយរដ្ឋធម្មនុញ្ញ បកស្រាយច្បាប់ ឬពិនិត្យធម្មនុញ្ញភាពនៃច្បាប់ណាដែលប្រកាសឱ្យប្រើហើយ។

ខ- ប្រជារាស្ត្រ អាចប្តឹងទៅតុលាការអំពីអធម្មនុញ្ញភាពនៃច្បាប់ ប្រសិនជាខ្លួនយល់ថា ច្បាប់ដែលអនុវត្តនោះមិនស្របនឹងរដ្ឋធម្មនុញ្ញ ឬក៏យល់ឃើញថា សេចក្តីសម្រេចរបស់ស្ថាប័នសាធារណៈ រំលោភទៅលើសិទ្ធិជាសារវន្តរបស់ខ្លួន ។

គ- ទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ប្រជារាស្ត្រអាចធ្វើបណ្តឹងឧទ្ធរណ៍ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងករណីមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាអាទិ៍ក្នុងករណីចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត ករណីបាត់ឈ្មោះពីបញ្ជីបោះឆ្នោត ឬប្តឹងជំទាស់នឹងការចុះឈ្មោះបោះឆ្នោត ឬការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

ទន្ទឹមនឹងនេះ នៅដំណាច់ឆ្នាំនីមួយៗ នៅពេលដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ប្រជារាស្ត្រអាចធ្វើបណ្តឹងឧទ្ធរណ៍មកក្រុមប្រឹក្សាធម្មនុញ្ញ អំពីការចុះឈ្មោះបោះឆ្នោត ឬការបាត់ឈ្មោះពីបញ្ជីបោះឆ្នោត ឬប្តឹងជំទាស់នឹងការចុះឈ្មោះបោះឆ្នោត ឬការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ារបស់គណបក្សនយោបាយ ដែលក្រសួងមហាផ្ទៃបានបដិសេធមិនចុះក្នុងបញ្ជីគណបក្សនយោបាយ ។

អ្នកបោះឆ្នោត បេក្ខជន ឬអ្នកតំណាងគណបក្សនយោបាយគ្រប់រូបអាចប្តឹងជំទាស់នឹងការបោះឆ្នោតបាន ក្នុងករណីមានការភ័ន្តច្រឡំ ភាពមិន

ប្រក្រតី ឬការបន្លំ។ ដូច្នេះលទ្ធភាពប្ដឹងជំទាស់នឹងលទ្ធផលនៃការបោះឆ្នោត ត្រូវបានធានាទំរង់តាមផ្លូវច្បាប់។

វិវាទក្នុងការបោះឆ្នោត ជាសមត្ថកិច្ចរបស់គណៈកម្មការ ខេត្ត ក្រុង រៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ក្រុមប្រឹក្សាធម្មនុញ្ញ។ នៅពេលដែលអាជ្ញាធរទាំងអស់នេះ ត្រូវកាត់ក្ដីលើបណ្ដឹងជំទាស់ណាមួយ អាជ្ញាធរទាំងនេះអនុវត្តមុខងារនៃយុត្តាធិការ។ ដូច្នេះ ចៅក្រមត្រូវតែរកដំណោះស្រាយឱ្យបានច្បាស់លាស់ ដើម្បីធានាឱ្យមានភាពស្មោះត្រង់ ចំពោះសន្លឹកឆ្នោត និង ធម្មានុរូបភាពតាមលក្ខណៈប្រជាធិបតេយ្យ ( តាមភាពស្របច្បាប់ ឬ តាមភាពត្រូវច្បាប់ ) ដែលជឿជាក់បាន និង មិនអាចប្រកែកបាន។

តួនាទីរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងការពិនិត្យ និង សម្រេចអំពីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និង តំណាងរាស្ត្រ មានចែងក្នុងមាត្រា ១៣៦ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ មាត្រា ២៩ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា មាត្រា ២៥ថ្មី មាត្រា ២៧ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង មាត្រា ៤២ថ្មី មាត្រា ៤៣ មាត្រា ៦២ថ្មី មាត្រា ៦៦ថ្មី មាត្រា ៧៣ថ្មី មាត្រា ១១៤ មាត្រា ១១៧ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

ការពិនិត្យសម្រេចអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោត មានចាប់

ពីដំណាក់កាលនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និង បញ្ជីបេក្ខជនឈរឈ្មោះ ការចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ការឃោសនាបោះឆ្នោត ក៏ដូចជាលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត។

ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលពាក្យបណ្ដឹងដោយផ្ទាល់ក្នុងករណីខ្លះ។ សម្រាប់ពាក្យបណ្ដឹងដែលធ្វើឡើងដោយបុគ្គលមួយរូប ឬគណបក្សនយោបាយដែលជាបេក្ខជននៃការបោះឆ្នោត និង ជាអ្នកជំទាស់ទៅនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត (មាត្រា ២៧ថ្មី ចំណុចទី១ នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ)។ ក្នុងករណីនេះ ពាក្យបណ្ដឹងត្រូវដាក់ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលណ្ដោះអាសន្ន។ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពាក្យបណ្ដឹងក្នុងរយៈពេល ២០ថ្ងៃ ដោយគិតពីថ្ងៃបានទទួលពាក្យបណ្ដឹង ( មាត្រា ២៧ថ្មី វាក្យខ័ណ្ឌទី២ នៃច្បាប់ស្ដីពីវិសោធកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ)។

សូមបញ្ជាក់ជូនផងដែរថា ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចសេចក្ដីតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកទាំងមូល។ ក្នុងករណីដែលបែកសម្លេងជាពីរស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាសម្លេងឧត្ដមានុភាព។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជាក់អំពីហេតុផល ។

មាត្រា ១៤២ ថ្មី ចែងថា "បទប្បញ្ញត្តិក្នុងមាត្រាណា ដែលក្រុម-ប្រឹក្សាធម្មនុញ្ញប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាស

ឱ្យប្រើ ឬយកទៅអនុវត្តបានឡើយ” ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺ ជាសេចក្តីសម្រេចចុងក្រោយ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ជូនប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ប្រធានតុលាការកំពូល និងចុះផ្សាយក្នុងរាជកិច្ច ។

ប្រធានព្រឹទ្ធសភា ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិកព្រឹទ្ធសភាទាំងអស់ ។

ប្រធានរដ្ឋសភា ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិករដ្ឋសភាទាំងអស់ ។

នាយករដ្ឋមន្ត្រី ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិករាជរដ្ឋាភិបាលទាំងអស់ ។

ប្រធានតុលាការកំពូល ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់តុលាការសាមី ។

សូមគូសបញ្ជាក់ចុងក្រោយថា ជនណាដែលមានពិរុទ្ធបានធ្វើជាសាក្សីទុច្ចរិត ឬធ្វើការកៀបសង្កត់ទៅលើសាក្សី ក្នុងក្របខ័ណ្ឌនៃការអង្កេតស៊ើបសួររបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឬជនណាដែលមិនព្រមគោរពតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឬរារាំងដល់កិច្ចប្រតិបត្តិការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ដល់ ១ឆ្នាំ និង

ត្រូវពិន័យជាប្រាក់ ពីដប់ម៉ឺន (១០០.០០០) រៀល ដល់ហុកសិបម៉ឺន (៦០០.០០០) រៀល ឬផ្តន្ទាទោសណាមួយក្នុងចំណោមទោសទាំងពីរ ។

ខ្ញុំសូមបិទវង់ក្រចកវិញ ដើម្បីបន្តការស្វែងយល់អំពីរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។

ជំពូកទី១៣ថ្មី អំពីការគ្រប់គ្រងរដ្ឋបាល មាន ០២ មាត្រា គឺពីមាត្រា ១៤៥ ថ្មី (មួយ) និង មាត្រា ១៤៦ ថ្មី ( មួយ ) ដែលចែងថា " ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ " ។

ជំពូកទី ១៤ ថ្មី អំពីសមាជជាតិ មាន ០៣ មាត្រា គឺពីមាត្រា ១៤៧ ថ្មី(មាត្រា ១២៨ ចាស់)ដល់មាត្រា ១៤៩ ថ្មី ដើម្បីបើកឱ្យប្រជារាស្ត្រជ្រាបដោយផ្ទាល់អំពីកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិ និង លើកបញ្ហាសំណូមពរជូនរដ្ឋអំណាចដោះស្រាយ ។

ជំពូកទី ១៥ ថ្មី អំពីអានុភាព ការសើរើ និង វិសោធនកម្មរដ្ឋធម្មនុញ្ញ មាន ០៤ មាត្រា គឺ ពីមាត្រា ១៥០ ថ្មី(មាត្រា ១៣១ ចាស់) ដល់មាត្រា ១៥៣ ថ្មី (មាត្រា ១៣៤ ចាស់ ) ដែលមានចែងជាអាទិ៍ថា : ការផ្តើមគំនិតសើរើ ឬ ការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និង របស់ប្រធានរដ្ឋសភាតាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួន (១/៤) នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។ ការសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើង

ដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើន ពីរភាគបី (២/៣) នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឱ្យធ្វើនៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្ន ។ ការសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញ មិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និង របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចមិនអាចសុំកែប្រែបានជាដាច់ខាត ។

ជំពូកទី ១៦ ថ្មី អំពីអន្តរប្បញ្ញត្តិ មាន ៥ មាត្រា គឺពីមាត្រា ១៥៤ថ្មី ដល់មាត្រា ១៥៨ថ្មី (មាត្រា ១៣៩ ចាស់ )ដែលមានចែងថា : រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឱ្យចូលជាធរមានភ្លាមដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា ។

ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមលក្ខខណ្ឌ ដែលមានចែងក្នុង មាត្រា ១៣ ថ្មី និង មាត្រា ១៤ ។

នីតិកាលទី១នៃព្រឹទ្ធសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

សម្រាប់នីតិកាលទី១នៃព្រឹទ្ធសភា : ①សមាជិកព្រឹទ្ធសភាមានចំនួនសរុបហុកសិបមួយរូប ②ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២នៃព្រឹទ្ធសភា ③សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា ④កិច្ចប្រជុំជាសមាជរដ្ឋសភានិងព្រឹទ្ធសភាត្រូវដឹកនាំដោយសហប្រធាន ។

ច្បាប់ និង លិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និង ទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និង ដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬ លុបចោលលើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០១១
ដោយឯកឧត្តម **ម៉ែន ចុល** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញជ្រើសតាំងដោយរដ្ឋសភា ។